**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

ក្នុងស្មារតីបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីតលើវិស័យការងារនិងអភិវឌ្ឍធនធានមនុស្ស ជាពិសេសការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ពលករខ្មែរ ដែលទៅបម្រើការងារនៅព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីតដោយស្របច្បាប់នោះ ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំគណៈប្រតិភូកម្ពុជាទៅទស្សនកិច្ច និងជួបពិភាក្សាការងារជាមួយសមភាគីរបស់ខ្លួន ដែលដឹកនាំដោយ ឯកឧត្តម Mofarrej S. Al-Hoquabani រដ្ឋមន្ត្រីក្រសួងការងារព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត ចាប់ពីថ្ងៃទី៩-១២ ខែកុម្ភៈ ឆ្នាំ២០១៦នៅទីក្រុងរីយ៉ាត ប្រទេសអារ៉ាប់ប៊ីសាអូឌីត។

នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលជាថ្ងៃទី២ នៃដំណើរទស្សនកិច្ច ឯកឧត្តម **អ៊ិត សំហេង** និង ឯកឧត្តម Mofarrej S. Al-Hoquabani បានឯកភាពចុះហត្ថលេខាលើកិច្ចព្រមព្រៀងចំនួនពីរគឺ៖

១-កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសពលករការងារផ្ទះ

២-កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសពលករការងារទូទៅ

កិច្ចព្រមព្រៀងទាំងនេះគឺជាឧបករណ៍ដ៏សំខាន់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ពលករខ្មែរ ដោយភាគីទាំងពីរត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងការជ្រើសរើស ការដាក់ឱ្យធ្វើការ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករដោយអនុលោមទៅតាមច្បាប់ និងបទដ្ឋានការងារសមរម្យ និងបទដ្ឋានសុវត្ថិភាពការងារ។ ភាគីទាំងពីរក៏ត្រូវបង្កើតគណៈកម្មការបច្ចេកទេសចំរុះមួយដើម្បីធ្វើការប្រជុំពិភាក្សាលម្អិត និងជាប្រចាំលើបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ។

ក្នុងអំឡុងពេលដំណើរទស្សនកិច្ចនេះ ឯកឧត្តមរដ្ឋមន្ត្រី **អ៊ិត សំហេង** រួមជាមួយឯកឧត្តម **អូស្មាន ហាសាន់** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីក៏បានឆ្លៀតពេលជួបសំណេះសំណាល និងរៀបចំអាហារសាមគ្គីដល់ក្មួយៗនិស្សិតខ្មែរ ដែលទទួលបានអាហារូបករណ៍របស់រាជរដ្ឋាភិបាលអារ៉ាប៊ីសាអូឌីត និងកំពុងសិក្សានៅតាមសាកលវិទ្យាល័យនានាក្នុងទីក្រុងរីយ៉ាតចំនួន១៨នាក់។ ក្នុងឱកាសនោះឯកឧត្តមរដ្ឋមន្ត្រីបានពាំនាំនូវក្តីនឹករឮក និងការផ្តាំផ្ញើរសួរសុខទុក្ខរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដល់ក្មួយៗនិស្សិតទាំង១៨រូប និងបានផ្តល់ថវិកាមួយចំនួនសម្រាប់ទិញសម្ភារៈសិក្សាផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន

*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦*

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៨៣ ៧៨ និងទូរសារ :(០២៣)៨៨ ២៧ ៦៥